N° 9

Kambuja suriya-

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៥ ខែកញ្ញា លេខ ៩

Sept-

ព.ស. ២៤៩៦ — គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| — សារាណីយធម៌ . . . . . . . . . . . . . . | ព្រះមហា ប៉ាច់ – សៀង . . . . . | ៦៤៣ |
| — កបិលកថា (តមក) . . . . . . . . . . . . | ព្រះមហាឧត្តមវង្សា កែ - អឿន . . . | ៦៥៦ |
| — ខ្លួនមនុស្សទុកដូចជាផ្ទាំង . . . . . . . . . | លោក ស៊ុន—ហ៊ាន . . . . . . . | ៦៦៥ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ការបណ្ដុះនិស្ស័យ (តមក) . . . . . . . | ព្រះមហាឧត្តមវង្សា ប៊ុង – ប៉ីម . . . | ៦៦៩ |
| — រឿងសាមកុក (តមក) . . . . . . . . . . | ឧកញ៉ា នូ – កន . . . . . . . . . . | ៦៧៥ |
| — រឿងអាវ័ក្សថ្លែងរឿងថ្លៃប្រាំ (តមក) . . . | លោក វ៉ាយ – ប៊ុក . . . . . . . . . | ៦៨៦ |
| — រឿងចិញ្ចៀនទិព្វ (តមក) . . . . . . . . . | អ្នកស្រីសារីយ៉ាន់ . . . . . . . . . | ៦៩០ |
| — រឿងប៉ូលនិងវីរ៍ស៊ីនី (តមក) . . . . . . . | លោក ផេង – ត្រឹវ . . . . . . . . . | ៦៩៥ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីដើមកំណើតរឿងរាមកេរ្តិ៍ . . . | លោកបាប– ពិន . . . . . . . . | ៧០៣ |
| **កំណត់នីប្រវត្តិការណ៍** | | |
| —សុន្ទរកថាបណ្ឌិតម៉ាឡាល៉ាសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ . . . | ៧១៤ |


មួយឆ្នាំមាស ១២ សៀវភៅ — ដំឡៃជាវ ១៩២រ. ០០

## សាភណីយធម៌

## ព្រះមហាបន្ទសិរី ជាប់-សឿង

ទេសនាផាក់វិទ្យុប្រទេសកម្ពុជា កាលពីថ្ងៃ ៨ រោចខែចេត្រឆ្នាំជូតសំរឹទ្ធិស័ក

ព.ស. ២៤៩១ (២១-៤-៤៨)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការថ្វាយបង្គំ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយគោរព) ។

តអំពីនេះទៅ សូមសំដែង សាភណីយធម៌ ផ្សាយតាមវិទ្យុទៃគ្យា-សទសព្វ តាមសមគួរដល់កាលវេលា ។

ពាក្យថា “សាភណីយធម៌” នេះ ប្រែថា “ធម៌ដែលបុគ្គលគប្បីរឭក” ចែកចេញជាមេមាតិកាមាន ៦ យ៉ាង គឺ ៖

១.– កាយកម្មប្រកបដោយមេត្តា

២.– វចីកម្មប្រកបដោយមេត្តា

៣.– មនោកម្មប្រកបដោយមេត្តា

៤.– ចែកលាភដែលបានមកដោយធម៌ដល់គ្នា

៥.– រក្សាសីលឲ្យបរិសុទ្ធស្មើគ្នា

៦.– បញ្ញាយល់ឃើញត្រូវគ្នា ។

សូមលើកយកបទមាតិកាមួយម្តងៗ មកអធិប្បាយពន្រ្លឹកសេចក្តី ដូចតទៅនេះ ៖

**កាយកម្មប្រកបដោយមេត្តា** — មុននឹងអធិប្បាយបទមាតិកានេះ សូមដកយកពាក្យ "មេត្តា" មកប្រែនិងអធិប្បាយជាតួយ៉ាងខាងដើមសិន ។

មេត្តា ប្រែថា "មេត្រី, សេចក្តីស្និទ្ធ, ការរាប់អាន, សេចក្តីស្រឡាញ់, ធម្មជាតិដែលមានក្នុងមិត្រ ឬប្រព្រឹត្តទៅដល់មិត្រ" ។ បើសំដែងតាមលក្ខណៈ, កិច្ច, ផល និងអាសន្នហេតុវិញ មេត្តានេះមានការប្រព្រឹត្តទៅដោយអាការជាប្រយោជន៍ ជាលក្ខណៈ (គ្រឿងកំណត់កត់សំគាល់), មានការប្រមូលទុកនូវប្រយោជន៍ ជាកិច្ច (ភ្នាក់ងារការៈ), មានការកំចាត់បង់នូវគំនុំគុំគួន ជាផល, មានការឃើញនូវសភាពជាទីគាប់ចិត្តពេញប្រាថ្នានៃសត្វទាំងឡាយ ជាអាសន្នហេតុ ។

កាយកម្មប្រកបដោយមេត្តានេះ មានអត្ថាធិប្បាយថា មនុស្សនិករគ្រប់ជាតិ-ភាសា ដែលឧប្បត្តិឡើងក្នុងភពនៃលោកទាំងមូលនេះ ទោះរួមសញ្ជាតិ រួមភេទ រួមទីលំនៅក្តីមិនបានស្រុកទេសជាមួយគ្នាក៏ដោយ ផ្សេងគ្នាក៏ដោយ សុទ្ធតែមានការប្រស្រ័យជាប់ទាក់ទងរកគ្នាជាដរាប ។ គ្មាននរណាមួយកើតមក រស់នៅតែឯកឯង ដោយគ្មានការប្រស្រ័យរកគ្នាទេ ។ ឯគោលការណ៍ប្រស្រ័យគ្នា មានត្រឹមតែ ៣ យ៉ាងគឺ: ១– ខាងផ្លូវកាយ, ២– ខាងផ្លូវសំដី, ៣– ខាងផ្លូវចិត្ត ។

ចំពោះមាតិកានេះ, ទសំខាន់បំផុត ជនរួមសញ្ជាតិភាសា រួមលទ្ធិ មិនត្រូវប្រតិបត្តិដូចគ្នា ត្រូវធ្វើជាដាច់ខាត ។ កិច្ចការទាំងពួងតាំងពីការងារតូចតាចបន្តិចបន្តួច មានការថែសំអាតជួសជុលទីលំនៅជាដើម រហូតដល់ការងារធំៗ, កាលបើកើតឡើងក្នុងពួកក្រុមនីមួយៗ ហើយ មិនត្រូវធ្វើកាយឲ្យរឹងតាំងឬមើលនឹងកែក្លក ចិត្តព្រងើយកន្តើយឥតរវីរវល់ទេ ត្រូវនាំគ្នាខ្នះខ្នែងយកចិត្តទុកដាក់ ចាប់នេះលើកនោះជ្រោមជ្រែងធ្វើកិច្ចការនោះៗ លុះត្រាតែបានសម្រេច ។

ម្យ៉ាងទៀត ពួកជនដែលរួមសង្គមជាមួយគ្នា មានគេតាពាធបៀតបៀន ទោះធ្ងន់ក្ដី ស្រាលក្ដី មិនត្រូវជំនើស មើលបំណាំទេ ត្រូវនាំគ្នាឈឺឆ្អាល ចាត់ចែងទឹកក្ដៅទឹកត្រជាក់ រកថ្នាំសង្កូវមកចុកដុសលាបស្រឡាប គក់ច្របាច់រឹតរួតរួតសរសៃដៃជើង បោកគក់លាងសំលៀកបំពាក់ទឹងសេនាសនៈ នៃអ្នកជំងឺឲ្យស្អាតបាតជាដើម ។ ការបំរើជំងឺនេះ គួរយកតម្រាប់ព្រះបរមគ្រូរបស់យើង កាលព្រះអង្គថែទាំជំងឺភិក្ខុមួយរូបឈ្មោះបូតិគត្តតិស្ស: ដោយព្រះហស្តព្រះអង្គ ជាតួយ៉ាង ។

មនុស្សណាដែលនៅក្នុងពួកក្រុមជាមួយគ្នា មិនរវីរវល់ មិនអើពើ ធ្វើដៃជើងឲ្យតាំងដូចស្លាប់ ធ្ងន់ដូចថ្មកំណល់កំរើកមិនរួច ឆាប់ស្លុតដូចផ្គត់ឈើ ក្នុងពេលមានកិច្ចរវល់កើតឡើងក្នុងពួកគណៈរបស់ខ្លួន, មនុស្សនោះ ទីងទៅជាអ្នកខ្វះមិត្ត ខ្វះការរាប់អាន រស់នៅកំព្រា

ពោលតែឯង ៗ ទីបំផុត គ្មានហេតុអ្វីដទៃ ក្រៅពីការត្រៀមមុខ ដេកគង់តែលើថ្វាសកើតទុក្ខ គួបចិត្តតឹងទ្រូង ថប់តែម្នាក់ឯង គង់ពេលមានទុក្ខធុរៈកើតឡើងចំពោះខ្លួននោះទេ ៗ ការយកចិត្តទុកដាក់ ជួយផ្តល់ធុរៈគ្នាដោយមេត្រីចិត្ត តែងជួបប្រទះនឹងគំនរសេចក្តីសុខចំរើន ដូចមានភាសិតសំដែងទុកថា អត្ថម្ហិ ជាតម្ហិ សុខា សហាយា “កាលបើមានកិច្ចរវល់កើតឡើង មិត្រសំឡាញ់ប្តូរគ្នាទាំងឡាយ តែងនាំសេចក្តីសុខមកឲ្យ ” ៗ

វចីកម្មប្រកបដោយមេត្តា — មានអត្ថាធិប្បាយថា សំដីសំដៅដែលត្រូវនិយាយទៅកាន់បុគ្គលដទៃ ក្នុងសង្គមជាមួយគ្នាម្តងៗ គួរប្រើវាចាល្អ ប្រកបដោយសេចក្តីពន្យល់តាមហេតុផល មានការប្រាប់បង្ហាញគោលការណ៍ពិត មកលាតត្រដាងឲ្យឃើញជាស់តៀន ចង្អុលប្រាប់គុណទោស, ល្អអាក្រក់, ត្រូវខុស, ហេតុមានប្រយោជន៍ ឥតប្រយោជន៍ ក្នុងបច្ចុប្បន្ននឹងបរលោកជាដើម ៗ ពេលនិយាយសោតទៀត គួរនិយាយឲ្យសមរម្យតាមគោលចារិកលក្ខណៈរបស់វាចាល្អទាំង ៥ យ៉ាង គឺ:

១— ពោលពាក្យតាមកាលគួរ សេចក្តីថា មុននឹងនិយាយ គួរពិចារណាមើលថា ពេលនេះ គួរអាត្មាអញនិយាយបានឬមិនបាន, បើឃើញថាគួរនិយាយ ក៏និយាយ បើមិនគួរទេក៏ឈប់ស្ងៀម ៗ

២.— ពោលពាក្យសច្ចៈ សេចក្ដីថា សំដីណាមិនកោះ មិនសារដើម មិនកែប្រែជាថ្មីទៀត ជាសំដីមិនមានពីរ ពោលទៀងទាត់ពិតមែន ហៅថាពាក្យសច្ចៈ ។ សំដីដែលយើងនិយាយក្នុងទីសន្និបាតម្ដងៗ មិនមែនចេញផុតពីមាត់ភ្លាម ហើយសាត់បាត់ទៅតាមលោកធាតុអាកាសទេ ទៀងតែនឹងចូលទៅកាន់ត្រចៀកបុគ្គលដទៃជាប្រាកដ ។ ហេតុនោះអ្នកនិយាយ ត្រូវស្វែងរកការពិតឲ្យឃើញ សឹមហាមាត់និយាយ ។ បើហេតុផលមិនពិតទេ ស៊ូព្រៀមស្ងៀម បិទប្រអប់មាត់ឲ្យជិតល្អជាង ។ ពាក្យសំដីពិតត្រង់ អាចធ្វើមនុស្សឲ្យមានតម្លៃបាន ទើបមានពាក្យបុរាណភាសិតថា “ស៊ីបង់ទ្រព្យកុំឲ្យបង់សំដី, មនុស្សគេយកសំដី ដំរីគេយកភ្លុក, ស្ងៀមជាជាងស្រដី, អណ្ដាតជាអាច៍កន្ធ បានសុខទុក្ខផងពីព្រោះអណ្ដាត” ។ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ប្រកបដោយវិចារណញ្ញាណ ឈ្វេងយល់ឃើញគុណានិសង្សនៃពាក្យសច្ចៈ ទើបប្រកាសសេចក្ដីពិតថា ៖

សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

“គួរឲ្យសរសើរពេក ពាក្យពិតជាពាក្យមិនចេះស្លាប់, ធម៌នេះជាប្រវេណីមានមកតាំងពីបុរាណ, សប្បុរសទាំងឡាយ បានតាំងនៅក្នុងហេតុនិងផលដ៏ពិតត្រង់” ។

មួយយ៉ាងទៀត ពាក្យសច្ចៈនេះ អាចឲ្យផលប្រច័ក្សជាក់ស្ដែងក្នុងបច្ចុប្បន្នទាន់ភ្នែកឃើញ គឺអាចការពារជីវិតខ្លួនឯងក្រុមគ្រួសារឲ្យផុតអំពីមរណភាពបាន, តួយ៉ាងដូចអង្គុត្តកសាមណេរនឹងមហាសុតសោម-បណ្ឌិតជាដើម ។ បានជាមានភាសិត ក្នុងគិទ្ធវគ្គ អដ្ឋកថាតក្ការិយ-ជាតក ក្នុងតេរសនិបាត ប្រកាសទុកមកថា ៖

តស្មា មរណតោ មោក្ខំ បត្ថយន្តេន ជន្តុនា
បហាយ អលិកំ សច្ចំ ភាសិតព្វំ សុធីមតា

“ព្រោះហេតុនោះ សត្វដែលមានប្រាជ្ញាល្អ កាលប្រាថ្នាឲ្យផុតអំពីមរណៈ ត្រូវលះបង់ពាក្យឡេះឡោះហោល ហើយពោលតែពាក្យពិតប៉ុះ” ។

៣.— ពោលពាក្យស្រទន់ផ្អែមល្ហែម គឺនិយាយពាក្យពីរោះល្អ នាំឲ្យអ្នកស្ដាប់កើតសេចក្ដីជ្រះថ្លាសោមនស្សបាន ។

៤.— ពោលពាក្យប្រកបដោយប្រយោជន៍ គឺពាក្យពោលពន្យល់ប្រាប់ហេតុផល នឹងការខុសត្រូវក្នុងបច្ចុប្បន្ននឹងបរលោក, ការនិយាយទូន្មាន ឲ្យចេះរៀបចំខ្លួនប្រាណមានរបៀបរៀបរយគ្រប់ឥរិយាបថទាំងបួន ស្លៀកដណ្ដប់បិទបាំងរាងកាយ នឹងដាស់គំនិតឲ្យដឹងការខុសត្រូវជ្រៅរាក់, ការនិយាយពន្យល់ប្រាប់ប្រយោជន៍ខាងកសិកម្ម ឲ្យខំព្យាយាមប្រឹងប្រែងស្វែងរកទ្រព្យសម្បត្តិ ដោយការភ្ជួររាស់កាប់គាស់

កកាយធរណី បណ្ដុះដាំស្រូវ, ពោត, សណ្ដែក, ល្ងនិងដំណាំនានា ជាបុព្វជាតិនិងអបរជាតិក្ដី ខាងពាណិជ្ជកម្ម ផ្ទំទិញដូរលក់ ទាំង ២ ពួកគឺ ជង្ឃពាណិជ (ឈ្មួញសំពាយ), សកដពាណិជ (ឈ្មួញទូករទេះកប៉ាល់និងឈ្មួញធម្មតាតាមផ្ទះផ្សារ) ក្ដី ហៅថាពោលពាក្យប្រកបដោយប្រយោជន៍ ៗ មួយយ៉ាងទៀត ការនិយាយសរសើរគុណសម្បត្តិវិជ្ជាសាស្ត្រដាស់គំនិតអ្នកស្ដាប់ឲ្យចូលចិត្ត ស្រឡាញ់ការសិក្សារៀនសូត្រដោយន័យថា នែកុមារកុមារីទាំងឡាយ! វិជ្ជាឬសាស្ត្រក្នុងលោកនេះច្រើនណាស់ តែបើបំប្រួញឲ្យខ្លីមកមានត្រឹមតែ ៥ យ៉ាងគឺ និតិវិជ្ជា បានដល់វិជ្ជាខាងការសិក្សារៀនសូត្រអក្សរសាស្ត្រ លេខនព្វន្តគុណហាជាដើម ១, យន្តវិជ្ជា បានដល់វិជ្ជាខាងគ្រឿងចក្រយន្ត (គ្រឿងម៉ាស៊ីន) ទាំងអស់ ១, វេជ្ជវិជ្ជា បានដល់វិជ្ជាពេទ្យហ្មចេះមន្តអាគមឬពេទ្យផ្សំថ្នាំ ១, រដ្ឋវិជ្ជា បានដល់វិជ្ជាខាងផ្លូវច្បាប់សម្រាប់ប្រទេស ១, យុទ្ធវិជ្ជា បានដល់វិជ្ជាចំបាំង ១ បណ្ដាវិជ្ជាឬសាស្ត្រទាំង ៥ យ៉ាងនេះ សុទ្ធតែមានប្រយោជន៍សម្រាប់ខ្លួននិងប្រទេសជាតិទាំងអស់, វិជ្ជាមិនដែលអាក្រក់ទេ មានតែមនុស្សទេតើទើបអាក្រក់, អ្នកត្រូវចំប្រឹងប្រែងសិក្សា ខាំមាត់អត់ធន់តស៊ូនឹងសេចក្ដីទុក្ខលំបាកគ្រប់យ៉ាង ប្ដូរយកវិជ្ជាសម្បត្តិណាមួយឲ្យបាន ទាន់ខ្លួនអ្នកកំពុងតាំងនៅក្នុងយោព្វនវ័យ ដើម្បីនឹងតែខ្លួនអ្នកឲ្យជាមនុស្សម្នាក់ ពិតនៅក្នុងឋានៈដ៏ខ្ពង់

ខ្ពស់ ព្រមទាំងលើកស្ទួយប្រទេសជាតិមាតុភូមិអ្នកឲ្យមានតម្លៃ ឃ្លាតឆ្ងាយពីហ៊ានភាពទន់ទាសភាពឡើង ហេតុនេះ ចូរអ្នកកុំខ្ជិលកុំទំរន់ទំលាក់ក្រាញផ្ញើអត្តភាពប្រហែលគ្នានឹងដង្គត់ឈើឬដុំថ្មឡើយ, អ្នកទាំងឡាយមិនធ្លាប់បានស្តាប់ទេឬ? ពាក្យសុភាសិតថា:

អបុត្តកំ ឃរំ សុញ្ញំ រដ្ឋំ សុញ្ញំ អរាជិកំ
អសិប្បស្ស មុខំ សុញ្ញំ សព្វសុញ្ញំ ទលិទ្ទកំ

ផ្ទះដែលឥតកូនសូន្យស្ងប់ស្ងាត់ ដែនដែលឥតក្សត្រសូន្យគាថ្ង
មាត់ឥតសិល្បសាស្ត្រសូន្យពាក្យបរពា ខ្សត់ក្រកំព្រាសូន្យសព្វទាំងអស់ ។

ការរង្វានពន្យល់ប៉ុណ្ណោះជាដើម ចាត់ជាក៏ជាប្រកបដោយប្រយោជន៍ផ្លូវបច្ចុប្បន្ន ។

ចំណែកខាងក៏ជាប្រកបដោយប្រយោជន៍ផ្លូវបរលោកវិញ បានដល់ការនិយាយដាស់តឿនឲ្យមានសទ្ធាជឿបុណ្យបាប, រក្សាសីល, លះលោភៈនិងមច្ឆរិយៈចេញ ហើយបរិច្ចាគទាន និងបញ្ញាសម្រាប់ពិចារណាឲ្យដឹងហេតុផលសព្វគ្រប់ រហូតដល់ការពិចារណាអត្តភាពថា ជាគ្រោងកាយបិតនៅក្នុងកណ្តាប់ដៃនៃសាមញ្ញលក្ខណធម៌ទាំង ៣ គឺ ទុក្ខំ, អនិច្ចំ, អនត្តា លម្មកើតធម្មសង្វេគចំពោះបញ្ចក្ខន្ធ ដោះខ្លួនគេចចេញចាកកពក់លវដ្តសង្សារដែលកំពុងឆេះសន្ធោសន្ធៅដោយភ្លើងទាំង ៣ គឺរាគៈទោសៈមោហៈ ។

វាចាប្រាសចាកប្រយោជន៍ បើទុកជាបុគ្គលអ្នកនិយាយប៉ប៉ោច ដូចលាផ្ទុះ តាំងពីព្រលឹមទល់ព្រលប់ ពីព្រលប់ទល់ភ្លឺក៏ដោយ មិនអាចយកទៅប្រៀបធៀបនឹងវាចាជាប្រយោជន៍ សូម្បីមួយបំណិតបានឡើយ ។ ព្រោះហេតុនោះ បានជាព្រះបរមគ្រូជាមហាអ្នកប្រាជ្ញទ្រង់ប្រកាសគាថា ទុកជាឧត្តមគតិថា:

សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ

“បុគ្គលស្តាប់នូវបទណា ហើយស្ងប់រម្ងាប់បាន, បទនោះជាបទមានប្រយោជន៍ សូម្បីតែមួយ គង់ប្រសើរជាងវាចាមួយពាន់ម៉ាត់ដែលមិនប្រកបដោយប្រយោជន៍” ។

៥.— ពោលពាក្យដោយចិត្តមេត្តា គឺនិយាយដោយសេចក្តីអនុគ្រោះអាណិតអាសូរ ព្រោះប្រាថ្នាឲ្យកើតប្រយោជន៍ពិតៗ មិនប្រាថ្នាកម្រៃអ្វី ។ អ្នកពោលវាចាល្អតាំង ៥ យ៉ាងនេះសឹងជាប្រយោជន៍ខ្លួននឹងអ្នកដទៃគ្រប់ៗ ១ ។

មនោកម្មប្រកបដោយមេត្តា.— មានអត្ថាធិប្បាយថាចិត្តដែលត្រិះរិះពិចារណា ស្រាវជ្រាវរករកមធ្យោបាយ ដោយសន្តិវិធី ចំពោះករណីយកិច្ចប្រកបដោយហេតុផល ដើម្បីញុំាងសន្តិសុខនឹងវារៈប្រយោជន៍ឲ្យកើតមានឡើងក្នុងសង្គមនីមួយៗ តាំងខំប្រឹងរិះរកកលឧបាយ

រក្សាការពារសេចក្ដីសុខនិងប្រយោជន៍ ដែលបានមកហើយឲ្យរឹងរឹតតែរឹងប៉ឹងបិតថេរទៅទៀត ហៅថាមនោកម្មប្រកបដោយមេត្តា ។ ការពិចារណាយល់កិច្ចការ តាំងចិត្តជាសប្បុរសរកគ្នាទៅវិញទៅមករវាងមនុស្សនិងមនុស្សផងគ្នាក្នុងគណៈជាមួយគ្នាបាន ចាត់ថាជាគុណសម្បត្តិមួយដ៏ប្រសើរបំផុត ព្រោះមានបុរាណភាសិតថា:

ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្លាស់
ក្របានជាធំ លើគេទាំងអស់ ក្រចិត្តសប្បុរស
និងមនុស្សផងគ្នា ។ ក្រធំបំផុត គឺក្រទីពឹងខាងចុង ។

ចែកលាភដែលបានមកដោយធម៌ដល់គ្នា — មានអត្ថាធិប្បាយថា លាភប្រកបដោយធម៌ ខាងបព្វជិត បានដល់ចតុប្បច្ច័យកើតឡើងអាស្រ័យកំឡាំងសទ្ធារបស់ខ្លួន ខំដើរស្វែងរកតាមច្រកល្អប្រាសចាកបាបធម៌ប្រាំ និងអនេសនៈម្ភៃមួយ ។ ពុំនោះសោតកើតឡើងដោយអាស្រ័យទាយកទាយិកា ជ្រះថ្លាក្នុងគុណសម្បត្តិនិងចរិយាសម្បត្តិខ្លួនហើយប្រគេនមក ។ ខាងគ្រហស្ថ បានដល់លាភសក្ការៈកើតឡើងត្រឹមត្រូវតាមធម៌ប្រាសចាកបញ្ចវេរជាដើម ។ លាភបែបនេះបើបានមកហើយ មិនគួរហួងហែងទុកសម្ងំបរិភោគប្រើប្រាស់តែឯងទេត្រូវចែកចាយគ្នាបរិភោគប្រើប្រាស់តាមមានតាមបាន ។ មនុស្សរួមសំរាំសម្ពុសង្គមជាមួយគ្នា បើបានលាភសក្ការៈមកហើយ លាក់លៀមទុក

បរិភោគប្រើប្រាស់តែម្នាក់ឯង ក្រេបសំឡឹងឃើញសេចក្ដីទុក្ខអ្នកដទៃ មិនខុសគ្នានឹងពីបុរាណភាសិតថា "ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្រុកទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង", ពុទ្ធភាសិតថា សក្ការោ កាបុរិសំ ហន្តិ "គ្រឿងសក្ការៈ តែងសម្លាប់បុគ្គលអាក្រក់" ដូច្នេះ ។

វាក្យសីលឲ្យបរិសុទ្ធស្មើគ្នា.— មានអត្ថាធិប្បាយថាអ្នកដែលកាន់វិរតិចេតនាវៀរគ្រប់សិក្ខាបទដែលខ្លួនសមាទានហើយ រៀបចំកាយទ្វារមនោទ្វារនឹងវចីទ្វារ ឲ្យមានរបៀបរៀបរយហៅថា អ្នកមានសីល ។ ការមិនចាប់កាន់គ្រឿងសស្ត្រាវុធ, ព្រនង់ដំបង ដោយហោចទៅសូម្បីបហរណវត្ថុដទៃៗទៀត ដើម្បីពិឃាតសត្វ ឈ្មោះថាជាគុណសម្បត្តិផ្នែកបាណាតិបាត ។ ការមិនលួចកាត់របងឬបើករបងច្រកល្ហកកាត់ទីតមានជញ្ជាំងផ្ទះ ពុះបំបែកតុទូ ឆក់ដណ្ដើមយកទ្រព្យសម្បត្តិអ្នកដទៃជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកអទិន្នាទាន ។ ការមិនកន្លងប្រវេណីធម៌ គឺមិនលួចគូនប្រពន្ធអ្នកដទៃ ដោយអាការៈកំហែងប្រើអំណាចជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកកាមេសុមិច្ឆាចារៈ ។ ការមិននិយាយកុហកភូតភរ ឈ្មោះថាជាគុណសម្បត្តិផ្នែកមុសាវាទ ។ ការមិនចាប់ពាល់ដបឬកែវ ដែលពេញដោយទឹកស្រវឹង មានសុរានឹងមេរ័យជាដើម ឈ្មោះថាជាគុណសម្បត្តិផ្នែកសុរាមេរ័យ ។

មនុស្សក្នុងក្រុមនីមួយៗ បើមានការវៀរបានដូចគ្នា ចំពោះសិក្ខាបទសម្រាប់ភេទរបស់ខ្លួនហើយ ឈ្មោះថាជាអ្នកមានសីលដូចគ្នា ៗ ចំពោះសមណភេទវិញ ក៏មានលំនាំដូចគ្នាផងៗ អ្នកនៅក្នុងសង្គមជាមួយគ្នា មានសីលស្មើគ្នា រមែងបានសេចក្តីសុខសេចក្តីចំរើន សព្វពេលវេលា ៗ

**បញ្ញាយល់ឃើញត្រូវគ្នា**.— មានអត្ថាធិប្បាយថា ទិដ្ឋិនេះជាតួបញ្ញា បានដល់ញាណម្យ៉ាងសម្រាប់ពិចារណារកហេតុផលសព្វគ្រប់ ៗ ជនមានចំនួនច្រើន រួមសង្គមជាមួយគ្នា ត្រូវប្រើគំនិតឲ្យស្របគ្នា គឺមានការយល់ឃើញចំពោះប្រយោជន៍ ក្នុងសង្គមជាមួយគ្នាតែម្យ៉ាង ៗ ដ្បិតការយល់ឃើញផ្ទុយគ្នា ខុសឃ្លាងគ្នា មួយទៅឆ្វេងមួយទៅស្តាំ ទុកជាជាទោសមួយយ៉ាងធំ អាចរំលាយមិត្តសាមគ្គី ព្រមទាំងសន្តិសុខនិងប្រយោជន៍ គ្រប់ស្ថានក្នុងសង្គមឲ្យរលាយបាន ៗ

## ប្រយោជន៍របស់សារាណីយធម៌នោះមាន ៦ យ៉ាង គឺ

១.– ជាទីស្រឡាញ់ពេញចិត្តអ្នកដទៃ

២.– ជាទីគោរពរាប់អានអ្នកដទៃ

៣.– បានសេចក្តីសង្គ្រោះអំពីសំណាក់អ្នកដទៃ

៤.– មិនវិវាទទាស់ទែងខ្វែងគំនិតនឹងអ្នកណាមួយឡើយ

៥.– សាមគ្គីធម៌តែងកើតមានឡើង

៦.– មានការយល់ឃើញត្រូវគ្នា ៗ

*សំដែងធម៌ទេសនា អំពីសារាណីយធម៌ ល្មមសមគួរដល់កាលវេលាតែប៉ុណ្ណេះ ។*

*ទីបំផុតនេះ សូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រមទាំងអាណាប្រជារាស្ត្រ ក្នុងព្រះរាជអាណាចក្រទាំងមូល សូមឲ្យបានប្រកបដោយសុខភាពនិងវឌ្ឍនធម៌គ្រប់យ៉ាងកុំបីឃ្លាតឡើយ ! ។*

រតនត្តយតេជេន កម្មោជវជ្ជិរាសិនោ

វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សត្តិភាវញ្ច ឆាញ្ញហិ

*ដោយតេជះនៃព្រះរតនត្រ័យ សូមឲ្យប្រជាជននៅក្នុងកម្ពុជរដ្ឋ ដល់នូវសេចក្តីចំរើនលូតលាស់ និងសន្តិភាព កុំបីឃ្លាតឆ្ងាយទៅជាបការៈដទៃឡើយ ! ។*

បរិយាយអំពីសារាណីយធម៌ ចប់តែប៉ុណ្ណេះ

ធ្វើម្តេចប្រទេសជាតិនឹងចំរើន!

ប្រទេសជាតិនឹងចំរើនរុងរឿង ដោយសារមានប្រជារាស្ត្រច្រើន ហើយប្រជារាស្ត្រនោះមានសាមគ្គីធម៌ មិនមែនមកពីអ្នកមានសម្បត្តិទ្រព្យបីបួននាក់នោះទេ ។

យ. អ.